# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 991

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងពិពិធកម្មវិស័យកសិកម្មកម្ពុជា

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 03/07/19 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/07/27 |
| ៣. ចំណាយគម្រោងសរុប | $101,670,062 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| RESPONSIBLE UNIT | Project Coordination Office, MAFF |
| អង្គភាពទទួលខុសត្រូវ | អង្គភាពសម្របសម្រួលគម្រោង |
| ៥. ស្ថានភាពគម្រោង | គម្រោងកំពុងដំណើរការ |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងវិនិយោគជាទុន |
| ៧. ប្រភពហិរញ្ញប្បទាន៖ | ឥណទានសម្បទាន |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ពិពិធកម្មខ្សែច្រវាក់តម្លៃកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

## ១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កសិកម្ម និងការគ្រប់គ្រងដីធ្លី

**១២. ទីតាំងអនុវត្តគម្រោង** (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

**កំពង់ចាម, មណ្ឌលគិរី, កំពង់ធំ, ឧត្ដរមានជ័យ, សៀមរាប, ព្រះវិហារ, បន្ទាយមានជ័យ, ក្រចេះ, បាត់ដំបង, ពោធិ៍សាត់, កំពង់ឆ្នាំង, ត្បូងឃ្មុំ , តាកែវ, ស្ទឹងត្រែង, រតនគិរី, រាជធានីភ្នំពេញ, កណ្តាល, កំពង់ស្ពឺ,**

**១៣. គោលបំណងរបស់គម្រោង** (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

**ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍសង្វាក់តម្លៃផលិតផលវិស័យកសិកម្ម ដែលមានលក្ខណៈពិពិធកម្ម នៅតាមទីតាំងភូមិសាស្ត្រមួយចំនួននៅកម្ពុជា និងផ្តល់ការឆ្លើយតបជាបន្ទាន់ ប្រកបដោយប្រសិទ្ធភាព ក្នុងករណីដែលមានវិបត្តិ ឬស្ថានភាពអាសន្ន ដែលបំពេញទៅតាមលក្ខណៈសមស្រប ដើម្បីទទួលបានការគាំទ្រពីគម្រោងនេះ។**

**១៤. ការពិពណ៌នាអំពីគម្រោង** (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

**គម្រោង CASDP ត្រូវបានតាក់តែងឡើង ដើម្បីបង្កើនឱកាសទីផ្សារ និងការធ្វើពិពិធកម្មកសិកម្ម ដោយប្រើប្រាស់អភិក្រមបែបបរិយាបន្ន ដោយអ្នកទទួលផលជាអ្នកដឹកនាំ។ គម្រោងនេះបែងចែកជាបីសមាសភាគ បូករួមនឹងសមាសភាគទី ៤ ដែលពុំមានការវិភាជន៍ធនធានទុក សម្រាប់ករណីដែលមានវិបត្តិ ឬស្ថានភាពអាសន្ន ដែលបំពេញទៅតាមលក្ខណៈវិនិច្ឆ័យសមស្រប ដើម្បីទទួលបានការគាំទ្រពីគម្រោង។ សមាសភាគទី ១ គឺជាផ្នែកដ៏ធំនៃការវិយោគទាំងនេះ ហើយគឺជាសមាសភាគដែលអនុវត្តជាម៉ូឌុល និងអាចពង្រីក និងកែសម្រួលឱ្យស្របទៅតាមទីតាំងភូមិសាស្ត្រ និងផលិតផល/សង្វាក់តម្លៃ។ សមាសភាគទី ២ ផ្តោតលើការពង្រឹងស្ថាប័ន និងបង្កើនផលជះរយៈពេលវែងនៃការវិនិយោគ ដែលធ្វើឡើងក្នុងសមាសភាគទី ១ ក្នុងរយៈពេលមធ្យម និងរយៈពេលវែង ដោយធានានូវនិរន្តរភាព និងការពង្រីកអត្ថប្រយោជន៍ទូទាំងប្រទេសកម្ពុជា។ គម្រោងនេះមានបួនសមាសភាគ ដូចតទៅ៖ (ក) ការផ្តល់លទ្ធភាពឱ្យមានការធ្វើពិពិធកម្មកសិកម្ម, (ខ) ការលើកកម្ពស់ប្រព័ន្ធព័ត៌មានកសិកម្ម និងការគ្រប់គ្រងការត្រួតពិនិត្យគុណភាព, (គ) ការគ្រប់គ្រងគម្រោង និងការពិនិត្យតាមដាន និងវាយតម្លៃ និង (ឃ) ការឆ្លើយតបចំពោះស្ថានភាពអាសន្ន ជាយថាហេតុ។**

**១៥. យុត្តិកម្មលើគម្រោង** (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

**គម្រោងរួមចំណែកក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់ទី៤ និងផែនការអភិវឌ្ឍន៏វិស័យកសិកម្ម ២០១៩-២០២៣ ដែលបានផ្តោតទៅលើពិពិធកម្មខ្សែច្រវាក់តម្លៃកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ។**

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

**អ្នកទទួលផលផ្ទាល់ពីគម្រោងនេះ រួមមាន កសិករខ្នាតតូច និងខ្នាតមធ្យម ដែលត្រូវបានចងក្រងជាក្រុមអ្នកផលិត ឬជាសហគមន៍ និងបង្ហាញពីសក្តានុពល និងចំណាប់អារម្មណ៍ចង់អភិវឌ្ឍន៍ អាជីវកម្មកសិកម្មរបស់ពួកគេ និងអាជីវកម្មកសិកម្មខ្នាតតូច និងខ្នាតមធ្យម ដែលចាប់អារម្មណ៍ចង់សហការដោយផ្ទាល់ជាមួយកសិករ ដើម្បីរួមគ្នាអភិវឌ្ឍន៍អាជីវកម្ម/សង្វាក់តម្លៃរបស់ខ្លួន។ អ្នកទទួលផលដោយប្រយោលផ្សេងទៀត រួមមាន អ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ដែលត្រូវបានកែសម្អសម្រាប់លើកកម្ពស់ការភ្ជាប់ទំនាក់ទំនងជាមួយទីផ្សារ ផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ។ ការបង្កើនភាពអាចរកបាននូវទិន្នន័យ និងព័ត៌មាន និងលទ្ធភាពទទួលបានទិន្នន័យ និងព័ត៌មានទាំងនេះ ព្រមទាំងយន្តការធានាគុណភាព (ដូចជា ក្របខ័ណ្ឌនិយតកម្ម ហេដ្ឋារចនាសម្ព័ន្ធ) នឹងផ្តល់ជាប្រយោជន៍ដល់វិស័យទាំងមូល។**

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទានចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងមានការគិតគូរទៅលើការគាំពារសង្គមនិងបរិស្ថាន។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សុំា**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| **២០. វិស័យឬសកម្មភាពផ្សេងៗទៀត** | 50 | **ទាក់ទងមធ្យម** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងមានការគិតគូរទៅលើការគាំពារស្ត្រី និងកុមារ។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានបទពីសោធន៍ និងសមត្ថភាពគ្រប់គ្រាប់ក្នុងការអនុវត្តគម្រោង។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

- **សមាសភាគទី១៖ គាំទ្រឱ្យមានការធ្វើពិពិធកម្មកសិកម្ម**

**សកម្មភាពចម្បងដែលគាំទ្រដល់ការធ្វើពិពិធកម្មកសិកម្ម គឺពាក់ព័ន្ធទៅនឹងការគាំទ្រដល់សហគមន៍កសិកម្ម ដោយផ្តល់នូវទុននិនិយោគបំពេញបន្ថែម (Matching Grant) តាមរយៈភ្នាក់ងារអនុវត្តគម្រោងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF-EA) និងឱកាសទទួលបានសេវាឥណទាន (Credit Line) ពីគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមអនុវត្តគម្រោង (PFI) ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ភ្នាក់ងារអនុវត្តគម្រោងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF-IA)។**

**ដើម្បីទទួលបានការគាំទ្រខាងលើពីគម្រោង សហគមន៍កសិកម្មចាំបាច់ត្រូវរៀបចំសំណើពិពិធកម្មកសិកម្មនិងកសិធុរកិច្ច (DPr/BPr) និងផែនការពិពិធកម្មកសិកម្មនិងកសិធុរកិច្ច (DPI/BPI) ដោយមានការគាំទ្របច្ចេកទេសពីក្រុមការងារអ្នកផ្តល់សេវាបច្ចេកទេស (TSP) ដែលបានចុះកិច្ចសន្យាផ្តល់សេវាជាមួយគម្រោងពិពិធកម្មកសិកម្មកម្ពុជា រួចដាក់ជូន គណៈកម្មការវាយតម្លៃ (EC) និងគណៈកម្មការប្រឹក្សាយោបល់និងអនុម័ត (AEC) ដែលមានសមាសភាពមកពីតំណាងក្រសួងទាំងបួនខាងលើ និងវិស័យឯកជន ធ្វើការពិនិត្យ និងអនុម័ត។**

គិតត្រឹមខែមីនា ឆ្នាំ២០២៣នេះ ក្រុមការងារអ្នកផ្តល់សេវាបច្ចេកទេស (TSP) បានជួយគាំទ្រដល់សហគមន៍កសិកម្មចំនួន ៦៣ ក្នុងការរៀបចំសំណើពិពិធកម្មកសិកម្ម និងកសិធុរកិច្ច។ ក្នុងពេលជាមួយគ្នានេះដែរ ផែនការពិពិធកម្មចំនួន ៣៤ ក្នុងនោះមានផែនការកសិធុរកិច្ចចំនួន ៤០ ត្រូវបានគណៈកម្មការប្រឹក្សាយោបល់និងអនុម័តអនុញ្ញាតឱ្យទទួលបានហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ។ ក្នុងចំណោមផែនការពិពិធកម្មដែលបានអនុម័តខាងលើ ផែនការពិពិធកម្មចំនួន១៧ (ផែនការកសិធុរកិច្ចចំនួន ២៣) របស់សហគមន៍កសិកម្មចំនួន១៧ ត្រូវបានចុះកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ រួមមាន៖ ខេត្តកំពង់ចាមចំនួន ៣សហគមន៍ ខេត្តស្ទឹងត្រែងចំនួន ២សហគមន៍ ខេត្តបាត់ដំបងចំនួន ២សហគមន៍ ខេត្តព្រះវិហារចំនួន ៥សហគមន៍ ខេត្តកំពង់ស្ពឺចំនួន ៣សហគមន៍ និងខេត្តកំពង់ឆ្នាំង ២សហគមន៍ ដែលសរុបជាទឹកប្រាក់មានចំនួន ១ ៦៧៧ ៣៥៦ដុល្លារអាមេរិក សម្រាប់ធ្វើការវិនិយោគលើផលិតកម្មស្វាយចន្ទី ដំឡូងមី បន្លែសុវត្ថិភាព ស្លឹកគ្រៃ ផលិតកម្មមាន់សាច់ គោសាច់ ជ្រូកសាច់ និងចិញ្ចឹមឃ្មុំយកទឹក។

សមាសភាគនេះសម្រេចបានលទ្ធផលប្រមាណជា ២៥% នៃផែនការរួមរបស់គម្រោង។

- សមាសភាគទី២៖ គាំទ្រហេដ្ឋារចនាសម្ព័ន្ធសាធារណៈ

គម្រោងពិពិធកម្មកសិកម្មកម្ពុជា នឹងជួយគាំទ្រដល់ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈជនបទដូចជា៖ ១).ការស្តារប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ មានសមត្ថភាពស្រោចស្រពលើផ្ទៃដីចំនួន ១០ ០០០ ហិកតា និងសាងសង់ប្រព័ន្ធធារាសាស្ត្រថ្មីដែលមានសមត្ថភាពស្រោចស្រពលើផ្ទៃដីចំនួន ២ ០០០ ហិកតា ដែលអនុវត្តដោយភ្នាក់ងារអនុវត្តគម្រោងនៃក្រសួងធនធានទឹក និងឧតុនិយម និង២).កែលម្អផ្លូវជនបទដោយក្រាលកៅស៊ូប្រភេទ DBST ប្រវែង ១៧០គីឡូម៉ែត្រ និងក្រាលគ្រួសក្រហមប្រវែង ៨០គីឡូម៉ែត្រ ដែលអនុវត្តដោយភ្នាក់ងារអនុវត្តគម្រោងនៃក្រសួងអភិវឌ្ឍន៍ជនបទ ។

ក្នុងចំណោមសំណើរបស់សហគមន៍កសិកម្មទាំង ៦៣ ខាងលើ មានសំណើចំនួន ៤៣ ទទួលបានការអនុម័តពីគណៈកម្មការប្រឹក្សាយោបល់និងអនុម័ត បានស្នើសុំហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រដែលអាចស្រោចស្រពលើផ្ទៃដីប្រមាណ ១ ៦៦៤ ហិកតា រួមមាន ការស្តារស្រះសហគមន៍ចំនួន ៤កន្លែង ប្រព័ន្ធទឹកក្រោមដីចំនួន ១កន្លែង និងអាងស្តុកទឹកនិងប្រឡាយខ្នាតតូចចំនួន ៧កន្លែង។ ជាមួយគ្នានេះដែរ ក្រសួងអភិវឌ្ឍន៍ជនបទដែលជាភ្នាក់ងារអនុវត្តគម្រោងទទួលខុសត្រូវលើការធ្វើឱ្យប្រសើរឡើងផ្លូវលំជនបទ បានបញ្ចប់ការសិក្សាបឋមនូវផ្លូវដែលបានស្នើឡើងប្រវែង ៤១៦គីឡូម៉ែត្រ។

សមាសភាគនេះសម្រេចបានលទ្ធផលប្រមាណជា ១០% នៃផែនការរួមរបស់គម្រោង។

- សមាសភាគទី៣៖ ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធព័ត៌មានកសិកម្ម និងគ្រប់គ្រងការត្រួតពិនិត្យគុណភាព

សមាសភាគនេះត្រូវបានចូលរួមអនុវត្តដោយអង្គភាពជំនាញក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មួយចំនួនដូចជា អគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នាយកដ្ឋានកសិឧស្សាហកម្ម នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ដើម្បីគាំទ្រដល់ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធព័ត៌មានកសិកម្ម ទីផ្សារកសិកម្ម ការអនុវត្តប្រព័ន្ធអនាម័យ និងភូតគាមអនាម័យ ការគ្រប់គ្រងការកែច្នៃ និងសុវត្ថិភាពចំណីអាហារ។

ដើម្បីឈានទៅដល់ការសម្រេចបាននូវលទ្ធផលខាងលើ គិតត្រឹមខែមីនា ឆ្នាំ២០២៣ ក្រុមការងារអនុវត្តគម្រោងបានបញ្ចប់ការរៀបចំសេចក្តីព្រាងចុងក្រោយ ToR សម្រាប់ជ្រើសរើសអ្នកផ្តល់សេវាធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានកសិកម្ម (Agricultural Information System-AIS) និងបានដាក់ជូនធនាគារពិភពលោកដើម្បីអនុម័ត។

ជាមួយគ្នានេះផងដែរ អគ្គនាយកដ្ឋានកសិកម្ម និងអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានសម្រេចនូវសកម្មភាពមួយចំនួនដូចខាងក្រោម៖

o បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី ការអនុវត្តកសិកម្មល្អកម្ពុជា (CamGAP) ដល់មន្ត្រីអនុវត្តគម្រោងក្នុងរាជធានី ខេត្តគោលដៅទាំង១៣ ចំនួន ២វគ្គ

o រៀបចំសិក្ខាសាលាចំនួន ២លើកស្តីពីវិធានការអនាម័យ និងភូតគាមអនាម័យ (SPS) និងតម្រូវការសម្រាប់ការនាំចេញផលិតផលកសិកម្មពីប្រទេសកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ

o បានធ្វើការត្រួតពិនិត្យសត្វល្អិត (Pest Surveillance) លើដំណាំមៀន នៅខេត្តបាត់ដំបង ប៉ៃលិន រតនគិរី កំពង់ចាម ត្បូងឃ្មុំ និងក្រចេះ

o បានបញ្ចប់ការត្រួតពិនិត្យមន្ទីរពិសោធន៍សុខភាពសត្វ និងផលិតកម្មសត្វថ្នាក់កណ្ដាលមួយកន្លែង និងថ្នាក់តំបន់ចំនួន ៥កន្លែង ដើម្បីកំណត់តំបន់សម្រាប់ធ្វើការជួសជុល និងបានបញ្ចប់ការរចនាប្លង់បច្ចេកទេសស្ថានីយចត្តាឡីស័កចំនួន ១កន្លែង។

សមាសភាគនេះសម្រេចបានលទ្ធផលប្រមាណជា ១០% នៃផែនការរួមរបស់គម្រោង។

- សមាសភាគទី៤៖ ការគ្រប់គ្រង សម្របសម្រួល តាមដាននិងវាយតម្លៃគម្រោង

សមាសភាគនេះបានផ្ដោតសំខាន់លើការងារពាក់ព័ន្ធនឹងការសម្របសម្រួលការងារប្រតិបត្តិការគម្រោង ទាំងមូលដូចជា ការរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ (AWPB) ស្របតាមឯកសារគម្រោងដែលបានកំណត់ការរៀបចំសំណើសុំបុរេប្រទានថវិកានិងជម្រះបញ្ជីការជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារពិភពលោក ការតាមដាននិងវាយតម្លៃ (M&E) ប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS) ការគ្រប់គ្រងហិរញ្ញវត្ថុ កិច្ចលទ្ធកម្ម ការគាំពារបរិស្ថាននិងសង្គម និងការងារយេនឌ័រ។

ក្រុមការងារអនុវត្តគម្រោងបានចុះពិនិត្យតាមដានការអនុវត្តការងាររៀបចំសំណើនៅតាមសហគមន៍កសិកម្ម ការផ្ដល់ធាតុចូលកសិកម្មសម្រាប់ដំណាំបន្លែ ការចិញ្ចឹមមាន់ និងវារីវប្បកម្ម ដល់គ្រួសារទទួលផលនៃគម្រោងឆ្លើយតបបន្ទាន់ទៅនឹងជំងឺកូវីដ ១៩ ក្នុងក្របខ័ណ្ឌគម្រោងពិពិធកម្មកសិកម្មកម្ពុជា។

លើសពីនេះ គម្រោងបានរៀបចំនូវរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារពិភពលោក។ ក្រៅពីនេះ គម្រោងក៏បានរៀបចំវគ្គបណ្ដុះបណ្ដាលផ្សេងៗពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ ការទូទាត់ថវិកាចំណាយ និងការគាំពារបរិស្ថាននិងសង្គមដល់មន្ត្រីអនុវត្តគម្រោងថ្នាក់រាជធានីខេត្តទាំង១៣ផងដែរ។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្ដល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្ដានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

ធនាគារពិភពលោក

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្ដែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 1,872.7 | 0.0 | 1,101.6 | 565.6 | 0.0 | 0.0 | 565.6 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 347.9 | 0.0 | 206.0 | 103.0 | 0.0 | 0.0 | 103.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 1,524.8 | 0.0 | 895.6 | 462.6 | 0.0 | 0.0 | 462.6 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 16,703.0 | 0.0 | 7,723.7 | 1,030.9 | 0.0 | 0.0 | 1,030.9 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 1,111.0 | 0.0 | 421.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 3,378.6 | 0.0 | 1,804.3 | 313.4 | 0.0 | 0.0 | 313.4 | 0.0 |
| ទព្វសម្ភារៈ | 4,215.3 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ការបណ្តុះបណ្តាល | 2,498.1 | 0.0 | 1,498.4 | 217.5 | 0.0 | 0.0 | 217.5 | 0.0 |
| ផ្សេងៗ | 5,500.0 | 0.0 | 4,000.0 | 500.0 | 0.0 | 0.0 | 500.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 18,575.7 | 0.0 | 8,825.3 | 1,596.5 | 0.0 | 0.0 | 1,596.5 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 347.9 | 0.0 | 206.0 | 103.0 | 0.0 | 0.0 | 103.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 347.9 | 0.0 | 206.0 | 103.0 | 0.0 | 0.0 | 103.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 18,227.801 | 0.0 | 8,619.2 | 1,493.5 | 0.0 | 0.0 | 1,493.5 | |
| | | | | | | | | |
| World Bank | 18,227.801 | 0.0 | 8,619.2 | 1,493.5 | 0.0 | 0.0 | 1,493.5 | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 18,575.701 | 0.0 | 8,825.2 | 1,596.5 | 0.0 | 0.0 | 1,596.5 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | -0.001 | 0.0 | 0.1 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: